**The Royal Women's Hospital** Information for Women

**6. វិធីបង្ការកុំឲ្យមានផ្ទៃពោះ – Intra Uterine Device (IUD) (ឧបករណ៍ដាក់ក្នុងស្បូន)**

*ខែមេសា ឆ្នាំ 2004*

## 6. CONTRACEPTION – INTRA UTERINE DEVICE (IUD)

## ហេតុអ្វីបានជាប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ?

**ការបង្ការមិនឲ្យមានផ្ទៃពោះ គឺជាការចាំបាច់ បើអ្នកចង់ចៀសវាងផ្ទៃពោះដែលមិនចង់បាន និង ជំងឺកាមរោគ។**
រៀងរាល់ខែ អូវែររបស់ស្រ្តីផលិតពងមេជីវិតស្រ្តី។ នៅពេលដែលបុរសបញ្ចេញទឹកកាម ទឹកកាមនេះមានមេជីវិតបុរសរាប់លាន។ វាត្រូវការតែមេជីវិតបុរសនេះមួយប៉ុណ្ណោះ ដើម្បីចូលទៅបង្កាត់ក្នុងពងមេជីវិតស្រ្តី ហើយចាប់ផ្តើមមានផ្ទៃពោះ។ បើគូស្រករធ្វើការរួមរ័កនឹងគ្នា (លិង្គនៅក្នុងរន្ធយោនី) ហើយគ្មានការប្រុងប្រយ័ត្នជាមុនទេនោះ ស្រ្តីមានលទ្ធភាពខ្ពស់ក្នុងការមានផ្ទៃពោះ។ ការប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ អនុញ្ញាតឲ្យអ្នករួមរ័ក ហើយចៀសវាងការមានផ្ទៃពោះដោយអចេតនា។

## ស្រោមអនាម័យ មិនមែនជាគំនិតល្អជានិច្ចឡើយ

ប្រទេសអូស្រ្តាលី មានជំងឺកាមរោគថ្មីជាង 20 000 ក្នុងមួយឆ្នាំៗ។ ជំងឺកាមរោគទូទៅបំផុតគឺ chlamydia ដែលអាចធ្វើឲ្យមិនអាចមានកូនបាន បើទុកចោលមិនព្យាបាលទេនោះ។ ស្រោមអនាម័យគឺជាការការពារប្រសើរបំផុតរបស់អ្នកទល់នឹងជំងឺកាមរោគ។ បើអ្នកប្រើស្រោមអនាម័យនិងប្រេងធ្វើពីជាតិទឹក នៅរាល់ពេលដែលអ្នករួមភេទ អ្នកនឹងមានឱកាសតិចក្នុងការឆ្លង HIV/AIDS និងជំងឺកាមរោគ (STIs)។

## Intra Uterine Device (IUD) (ឧបករណ៍ដាក់ក្នុងស្បូន)

### តើ IUD គឺជាអ្វីទៅ?

IUD គឺជាឧបករណ៍តូចមួយសំរាប់បង្ការកុំឲ្យមានផ្ទៃពោះ ដែលត្រូវដាក់ទៅក្នុងស្បូនរបស់ស្រ្តី។ IUD មានពីរប្រភេទ :

- **IUD ទង់ដែង** គឺជាឧបករណ៍ប្លាស្ទិកតូចមួយ ដែលមានរុំទង់ដែងនៅជុំវិញគល់របស់វា។
- **Progestogen (Mirena) IUD** គឺជាឧបករណ៍តូចមួយមានរូបរាងដូចអក្សរ T ដោយមានបំពង់មួយដែលមានអ័រម៉ូន progestogen នៅជុំវិញគល់របស់វា។

## របៀបបំពេញមុខងាររបស់ IUD

ទោះជាគេបានប្រើ IUD អស់ពេលជាង 30 ឆ្នាំមកហើយដើម្បីបង្ការការមានផ្ទៃពោះក្តី ក៏គេនៅមិនទាន់យល់នូវរបៀបបំពេញមុខងាររបស់វានៅឡើយទេ។ IUD មានផលប៉ះពាល់ទៅលើចលនានិងភាពរស់រានមានជីវិតរបស់មេជីវិតបុរស នៅក្នុងស្បូន ដូច្នេះវាមិនអាចធ្វើដំណើរទៅដល់ពងមេជីវិតស្ត្រី ដើម្បីបង្កាត់ពងនេះបានទេ។ IUD ក៏ផ្លាស់ប្តូរដល់ស្រទាប់ក្នុងរបស់ស្បូន (endometrium) ផងដែរ ដើម្បីកុំឲ្យវាសក្តិសមនឹងមានផ្ទៃពោះ ហើយបង្ការកុំឲ្យពងមេជីវិតស្ត្រីបង្កទៅជាផ្ទៃពោះបាន បើវាពិតជាទទួលការបង្កាត់ដោយមេជីវិតបុរសមែននោះ។

### តើវាមានប្រសិទ្ធភាពយ៉ាងណាដែរ?

**IUD** មានប្រសិទ្ធភាពរវាង 95 និង 99 ភាគរយ ដែលប្រហែលគ្នានឹង The Pill "ថ្នាំគ្រាប់" (អានប័ណ្ណពត៌មាន វិធីបង្ការកុំឲ្យមានផ្ទៃពោះទី 3 *The Pill [ថ្នាំគ្រាប់]*)។

## គុណសម្បត្តិ និង គុណវិបត្តិនៃ IUD

### គុណសម្បត្តិ

ទាំង IUD ទង់ដែង និង ទាំង Mirena IUD មានផលប្រយោជន៍ដូចតទៅនេះ :

- បង្ការកុំឲ្យមានផ្ទៃពោះរយៈពេលយូរដែលមានប្រសិទ្ធភាព (យ៉ាងតិចប្រាំឆ្នាំ)
- ងាយស្រួលនឹងថែទាំ អ្នកមិនអាចភ្លេចប្រើវាដូចដែលអ្នកប្រហែលជាភ្លេចនៅពេលលេប The Pill (ថ្នាំគ្រាប់)នោះឡើយ
- វាមានតម្លៃថោកជាងវិធីបង្ការកុំឲ្យមានផ្ទៃពោះផ្សេងទៀត (ថ្លៃជាងនៅគ្រាដំបូង ប៉ុន្តែថោកជាងនៅរយៈពេលយូរ)
- បើអ្នកចង់មានផ្ទៃពោះ អ្នកអាចព្យាយាមមានផ្ទៃពោះនៅពេលមួយរំពេចបន្ទាប់ពីអ្នកដកវាចេញ។

**Progestogen (Mirena) IUD** បានបន្ថែមផលប្រយោជន៍នៃការកាត់បន្ថយការធ្លាក់ឈាមនៅពេលមានរដូវ។ នេះជាផលប្រយោជន៍ចំពោះស្ត្រីដែលជាធម្មតានឹងមានរដូវយូរពេលនិងធ្លាក់ឈាមច្រើន ឬស្ត្រីដែលមានរដូវរឹតតែយូរពេលនិងធ្លាក់ឈាមរឹតតែច្រើន នៅពេលប្រើ IUD ទង់ដែង។

### គុណវិបត្តិ

ទាំង IUD ទង់ដែង និង ទាំង Mirena IUD មានគុណវិបត្តិដូចតទៅនេះ :

- ទោះជាកំរក្តី នៅពេលដែល IUD គ្មានប្រសិទ្ធភាព ហើយស្ត្រីមានផ្ទៃពោះ ឧបករណ៍នេះត្រូវតែដកយកចេញយ៉ាងរហ័សតាមលទ្ធភាព។ IUD នៅក្នុងស្ត្រីមានផ្ទៃពោះ បង្កើនលទ្ធភាពគ្រោះថ្នាក់នៃការរលូតកូន
- IUD អាចខ្ទាតចេញពីស្បូនដោយខ្លួនវា ជាធម្មតាគឺក្នុងអម្លុងពេលមានរដូវ។ ស្ត្រីអាចមិនដឹងថា ហេតុការណ៍នេះបានកើតមានឡើងទេ ហើយគួរឆែកមើលជានិច្ចថា តើខ្សែរបស់វា នៅនឹងកន្លែងដែរឬទេ
- មានលទ្ធភាពគ្រោះថ្នាក់នៃដំបៅ នៅក្នុងពេលបីអាទិត្យ ក្រោយស៊កវាហើយ
- ដោយសារតែដំបៅនៅម្តុំសាច់ដុំឆ្អឹងត្រគាក អាចបណ្តាលឲ្យមិនអាចមានផ្ទៃពោះបាន វាជាការសំខាន់ណាស់ដែលស្ត្រីដែលដាក់ IUD ត្រូវប្រុងប្រយ័ត្នជាពិសេសអំពីការការពារខ្លួននឹងជំងឺកាមរោគ
- IUD អាចទម្លាយជញ្ជាំងស្បូន។ ហេតុការណ៍នេះកំរកើតមានណាស់ ហើយអាចកើតមាននៅពេលកំពុងស៊ក IUD
- មានលទ្ធភាពគ្រោះថ្នាក់នៃការមានកូនក្រៅស្បូនផងដែរ (ពេលដែលពងមេជីវិតស្ត្រីដែលបង្កាត់ហើយ ស្ថិតនៅក្នុងដៃស្បូន) នៅពេលដែល IUD គ្មានប្រសិទ្ធភាព (ហេតុការណ៍នេះកំរកើតមានណាស់ជាមួយនឹង IUD ទង់ដែង ហើយថែមទាំងរឹតតែកំរកើតមានជាមួយនឹង Progestogen IUD ទៀតផង)។

**Progestogen IUD** ក៏អាចមានផលវិបាកដូចតទៅនេះផងដែរ :

- ការធ្លាក់ឈាមឬរដូវមិនទៀងទាត់ ទំនងជាកើតមាននៅក្នុងពេលបីទៅប្រាំខែដំបូង។ យ៉ាងណាមិញ ជាយថាហេតុនោះ បើមានរដូវវិញនោះ ក៏អ្នកទំនងជាមានរដូវមួយចំនួនតូចដែរ នៅពេលប្រើ Progestogen IUD
- អាចបណ្តាលឲ្យទំនងជាមានកំណើនតិចតួច នៅក្នុងភាពស្លូតនៃរន្ធយោនី ក្តៅក្រហាល ឈឺក្បាល ចង្អោរ និង កើតមុន។

**IUD ទង់ដែង** អាចបណ្តាលឲ្យរដូវរបស់អ្នករឹតតែច្រើនឡើង និងឈឺចាប់ខ្លាំងឡើង

**អ្នកណាទៅដែលអាចប្រើ IUD?**

- ស្ត្រីដែលមានកូន
- ស្ត្រីមានលទ្ធភាពគ្រោះថ្នាក់តិចក្នុងការឆ្លងជំងឺកាមរោគ
- ស្ត្រីដែលមិនអាច ឬ មិនចង់លេប The Pill (ថ្នាំគ្រាប់)។

**អ្នកណាទៅដែលមិនគួរប្រើ IUD?**

- ស្ត្រីដែលមានលទ្ធភាពគ្រោះថ្នាក់យូរពេលក្នុងការឆ្លងជំងឺកាមរោគ (STIs) មិនគួរដាក់ IUD ទេ
- ស្ត្រីដែលមានការធ្លាក់ឈាមតាមរនយោនីដែលគ្មានរោគវិនិច្ឆ័យ
- ស្ត្រីដែលមានរោគរលាកម្តុំសាច់ដុំឆ្អឹងត្រគាក។

## ការដាក់ IUD

### ការរៀបចំ

មុនពេលអ្នកដាក់ IUD អ្នកគួរ :

- ធ្វើតេស្ត Pap smear (ដោះមាត់ស្បូន) និង swabs (ជូតស្បូន) ដើម្បីឲ្យដឹងប្រាកដថា ពុំមានដំបៅណាមួយនៅនឹងម្តុំសាច់ដុំឆ្អឹងត្រគាកឡើយ
- ធ្វើឲ្យប្រាកដថា អ្នកគ្មានផ្ទៃពោះឡើយ (ដូច្នេះ ត្រូវដាក់ IUD ភ្លាម នៅក្រោយពីអ្នកមានរដូវ ឬ ប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះដែលអាចទុកចិត្តបាន រហូតដល់ពេលអាចដាក់វា)។

### តើដាក់ IUD តាមរបៀបណា

អ្នកនឹងត្រូវដាក់នៅក្នុងគ្លីនិក នៅក្នុងទីតាំងប្រៀបដូចគ្នានឹងពេលដែលអ្នកនឹងហៀបធ្វើតេស្ត Pap smear យ៉ាងដូច្នោះដែរ។ ប្រដាប់សំរាប់រែកមួយនឹងត្រូវដាក់ទៅក្នុងរន្ធយោនីអ្នក ហើយកស្បូនអ្នកនឹងត្រូវជូតសម្អាតដោយទឹករម្ងាប់មេរោគ។ ប្រវែងរបស់ស្បូននឹងត្រូវវាស់វែង ហើយ IUD ត្រូវបានដាក់នៅខាងក្នុង តាមរយៈកស្បូន ឬផ្លូវបើករបស់ស្បូន។ ខ្សែរបស់ IUD ត្រូវបានកាត់ចេញ ដើម្បីឲ្យវាស្ថិតនៅខាងក្នុងរន្ធយោនី។ អ្នក ឬ ដៃគូរួមរ័ករបស់អ្នកនឹងមិនកត់សំគាល់ខ្សែនេះទេ ប៉ុន្តែអ្នកគួរតែអាចស្ទាបដឹងខ្សែនេះ បើអ្នកអាចលូកចូលទៅក្នុងរន្ធយោនីរបស់អ្នក។

អ្នកនឹងត្រូវរង់ចាំនៅឯគ្លីនិកនេះរយៈពេលប្រហែល 15 នាទី ដើម្បីធ្វើឲ្យប្រាកដថា អ្នកពិតជាគ្មានអារម្មណ៍នៃភាពមិនសុខស្រួលដែលមិនចាំបាច់ ឬ ការឈឺចាប់ឡើយ។

វាជាការសំខាន់ណាស់ដែលអ្នកមិនត្រូវរួមរ័ក ឬ ប្រើ tampons (វត្ថុស៊កពេលមានរដូវ) រយៈពេល 48 ម៉ោង ក្រោយពីដាក់ IUD ហើយ ដើម្បីបង្ការកុំមានដំបៅ។

## តើមានអ្វីកើតឡើងទៅ បើខ្ញុំមានអារម្មណ៍ថា មានអ្វីមួយមិនត្រឹមត្រូវបានកើតឡើងនោះ?

សូមទាក់ទងវេជ្ជបណ្ឌិតរបស់អ្នក នៅពេល :

- មានអារម្មណ៍ថា ខ្សែមានប្រវែងខ្លី ឬ វែងជាងធម្មតា ដោយសារតែ IUD អាចប្តូរទីតាំង។ វាជាការសំខាន់ណាស់ក្នុងការឆែកមើលប្រវែងខ្សែ ក្រោយពីមានរដូវម្តងៗ
- អ្នកឈឺពោះនៅផ្នែកខាងក្រោយដែលមិនបាត់ទៅវិញ ជាពិសេសនៅពេលកើតមានព្រមជាមួយនឹងគ្រុនក្តៅ
- អ្នកធ្លាក់ស ឬ ធ្លាក់ឈាមមិនធម្មតា ឬមានការឈឺចាប់នៅពេលរួមរ័ក
- អ្នក ឬ គូកំណាន់អ្នកធ្វើការរួមរ័កមួយផ្សេងទៀត ដែលបង្កើនលទ្ធភាពធ្វើឲ្យអ្នកមានជំងឺកាមរោគ
- ប្រាំមួយអាទិត្យក្រោយពីដាក់ IUD មក ហើយបន្ទាប់មក នៅរាល់ពេល 12 ខែម្តង

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women's Health Information Centre (RWH)**
(03) 8345 3045
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@thewomens.org.au
http://www.thewomens.org.au

**Choices Clinic នៅឯ Royal Women's Hospital**
កិច្ចបំរើអស់ថ្លៃតិច ដែលផ្តល់ឱវាទ ការពិគ្រោះយោបល់ និង ការព្យាបាលសំរាប់តម្រូវការទាំងអស់នៃវិធីបង្ការកុំឲ្យមានផ្ទៃពោះ និង សុខភាពផ្នែកភេទ។
ម៉ោងធ្វើការ : ថ្ងៃច័ន្ទ អង្គារ ព្រហស្បតិ៍ ម៉ោង 8:30 ព្រឹក ដល់ម៉ោង 11:30 ព្រឹក
ទូរស័ព្ទ : (03) 8345 2000

## ប័ណ្ណពត៌មានឯទៀតរបស់ RWH ដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើកមើលវិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ http://www.thewomens.org.au

អ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ Royal Women's Hospital ផ្តល់ប័ណ្ណពត៌មានឯទៀតអំពី វិធីបង្ការកុំឲ្យមានផ្ទៃពោះផងដែរ។ សុំយក :

ទី 1 *វិធីបង្ការកុំឲ្យមានផ្ទៃពោះ ជំរើសរបស់អ្នក*
ទី 2 *ស្រោមអនាម័យ និង ស្រោម Diaphragms*
ទី 3 *The Pill (ថ្នាំគ្រាប់)*
ទី 4 *Depo Provera - ថ្នាំចាក់បង្ការកុំឲ្យមានផ្ទៃពោះ*
ទី 5 *Implanon – ការវះផ្សាំបង្ការកុំឲ្យមានផ្ទៃពោះ*